## សេចក្តីជូនដំណឹង
## ស្តីពីសិក្ខាសាលាផ្សព្វផ្សាយលើកទី២ស្តីពី
## «ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូ រវាងរដ្ឋ និងឯកជន»

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកទី២ស្តីពី «ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន» ឬហៅជាភាសាអង់គ្លេសថា **«Law On Public-Private Partnerships»** និង «នីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន» ឬហៅជាភាសាអង់គ្លេសថា **«The Standard Operating Procedures for Public-Private Partnerships Projects»** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ០៨:៣០ ព្រឹក នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញភូគីត្រា ដើម្បីផ្សព្វផ្សាយឱ្យ កាន់តែទូលំទូលាយដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល, តំណាងដៃគូអភិវឌ្ឍន៍, ស្ថាប័នហិរញ្ញវត្ថុ, ក្រុមហ៊ុនទីប្រឹក្សាក្នុងវិស័យវិនិយោគសាធារណៈ, ក្រុមហ៊ុនមេធាវី, ក្រុមហ៊ុនធានារ៉ាប់រង និងវិស័យឯកជន។

សិក្ខាសាលាផ្សព្វផ្សាយនេះ នឹងប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត **ផាន់ ផល្លា** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គួរបញ្ជាក់ថា «**ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន**» បានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រម លេខនស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ និងបន្ទាប់មកក៏បានអនុម័ត និងដាក់ឱ្យប្រើ «**នីតិវិធីគ្រប់គ្រងប្រតិបត្តិការរួម សម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន**» តាមរយៈអនុក្រឹត្យលេខ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងរៀបចំការអនុវត្ត និងការគ្រប់គ្រងគម្រោង ភ.រ.ជ ឱ្យបានពេញលេញ និងមានប្រសិទ្ធភាពនៅកម្ពុជា។

អាស្រ័យហេតុនេះ សូមសាធារណជន និងអ្នកសារព័ត៌មានទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួម សិក្ខាសាលាលើកទី២ស្តីពី «**ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់ គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន**» ដែលនឹងប្រព្រឹត្តទៅដូចរៀបរាប់ខាងលើ កុំបីអាក់ខាន៕

សូមស្កេន QR Code ខាងក្រោមនេះ ដើម្បីទាញយកឯកសារពាក់ព័ន្ធសម្រាប់កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ៖